Free

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

www.khmerpostusa.com

FREE COPIES
Vol. 13. Issue #274
June 17, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email: Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

អ្នកស្រីក្រុមប្រឹក្សាក្រុងឡុងប៊ិច លីណាហ្គូន ហ្សាលេស ជាប់ឆ្នោត...

*Please Read Page 16*




នយោបាយកម្ពុជានៅគ្រប់ក្រឡាទាល់ច្រក

*Please Read Page 06*



"គ្រោដូជោ" **Grodojo** មានបង្រៀនក្បាច់គុនដល់កុមារនឹងមនុស្សធំ

*Please Read Page 04*



# មានការវិវត្តន៍ថ្មីពីបណ្ដឹងឱ្យប្ដូរប្រព័ន្ធបោះឆ្នោតនៅឡូវែល



លោក រិទ្ធី អ៊ុង



លោក វាសនា នួន



លោក វ៉ាឌី ម៉ម

ដោយ ពិន សំខុន

បន្ទាប់ពិការរារែកច្រើនឆ្នាំ នៅលើពាក្យបណ្ដឹងចំពោះសាលាក្រុងឡូវែលពីសំណាក់មេធាវីក្រុងជនជាតិភាគតិច មានប្រជាជនឡាទីណូ នឹងជនជាតិអាមេរិក មានដើមកំណើតអាស៊ីដែលតវ៉ាពីការរំលោភរដ្ឋធម្មនុញ្ញអាមេរីកាំងដោយគ្មានដំណាងក្នុងក្រុងជាជនជាតិភាគតិចដែលបានក្លាយជាអាមរីកាំង បើទោះជាទីក្រុងនោះមានជនភាតិភាកតិចចំនួនច្រើនជាងពាក់កណ្ដាលក៏ដោយ កាលពីថ្ងៃពុធមុន តុលាការបានសម្រេចឱ្យក្រុមប្រឹក្សាក្រុងឡូវែល ចុះសម្រុងគ្នាជាមួយនឹងមេធាវីដើមបណ្ដឹងឱ្យបានមុនថ្ងៃទី៤ខែធ្នូឆ្នាំ២០១៩ខាងមុខនេះ យកការប្ដូរប្រព័ន្ធបោះឆ្នោតថ្មីមួយ ដែលអនុញ្ញាត្តិឱ្យទីក្រុងឡូវែលអាចមានតំណាងជនជាតិភាគតិចអាចចូលរួមជាសមាជិកក្រុមប្រឹក្សាក្រុង ស្របតាមអត្ថន័យនៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកបច្ចុប្បន្ន។

ចាប់តាំងពីឆ្នាំ១៩៥៧មក សមាជិកក្រុមប្រឹក្សាក្រុងឡូវែលនេះ មានដំណាង៩រូប ដែលការបោះឆ្នោតធ្វើឡើងជាសាកល តែងតែផ្ដល់លទ្ធផលល្អៗឱ្យជនស្បែកស ធ្វើជាតំណាងនៅសាលាក្រុងជាដំរាប ឬពេលខ្លះក៏មានជនជាតិភាគតិច ចំនួនតិចតួចបានឈ្នះឆ្នោតម្ដងម្កាល ក៏ព្រោះតែក្រុមស្បែកស គេអនុគ្រោះឱ្យចូលជាក្រុមរបស់គេ ក៏ឆ្លងការបោះឆ្នោតរួចទៅ តែពុំមែនដោយសារតែសន្លឹកឆ្នោតសមត្ថភាពប្រជាជនភាគតិច ដែលរស់នៅក្នុងតំបន់ខ្លួនឯងនោះទេ ។ ស្ថិតិនៅពេលបោះឆ្នោតម្ដងៗ បានពន្យល់ថា "ប្រជាជនភាគតិចទាំងនោះ មិនបានយកចិត្តទុកដាក់ចេញទៅបោះឆ្នោតឱ្យបានច្រើនដូចប្រជាជនស្បែកសនោះទេ" ភាគច្រើនពុំបានយល់ពីការគ្រប់គ្រងដោយដំណាងសង្កាត់ដែលខ្លួនរស់នៅ គឺជាការផ្ដល់ផលប្រយោជន៏របស់ក្រុមគ្រួសារនឹងសហគមន៏ខ្លួននោះទេ។ ករណីចុងក្រោយនេះ គឺឧទាហណ៏លោក ឫទ្ធី អ៊ុង ពានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែលដំបូងគេបង្អស់ពីឆ្នាំ១៩៩៩ដល់២០០៥, នឹងលោក វាស្នា នួន បានជាប់ជាសមាជិកក្រុមប្រឹក្សាក្រុងឆ្នាំ២០១៥-១៦ នឹងឆ្នាំ២០១៨-សព្វថ្ងៃ, នឹងលោក វ៉ាឌី ម៉ម ជាប់ឆ្នោតជាតំណាងរដ្ឋឆ្នាំ២០១៦ ដល់សព្វថ្ងៃ។

តទៅទំព័រទី ២



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

*Excellent Service Since 1987*

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍

ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ

ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបំរើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

LAW OFFICE OF LOUIS S. HASKELL • 16 PINE STREET • LOWELL, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

តមកពីទំព័រទី ០១

# មានការវិវត្តន៍ថ្មីពីបណ្តឹងឱ្យប្តូរប្រព័ន្ធ...

ទីក្រុងឡូវែល គឺជាតំបន់ដែលសម្បូរជនជាតិអាមេរិកាំងដើមកំណើតខ្មែររស់នៅ នៅសង្កាត់លេខ ១៨ មានខ្មែរមិនតិចជាង៦05ទេដែលរស់នៅទីនោះ បើគិតសម្រាប់ទីក្រុងឡូវែលទាំងមូល គឺមានខ្មែរប្រមាណ៣0%លាយឡំនឹងពួកឡាទីណូ ពួកអាស៊ីប្រជុំកោះ ...មានផ្ទះសម្បែង មានគ្រួសារច្រើនតំណរ មានពាណិជ្ជកម្មខ្មែរ មានវត្តអារាមជាខ្មែរ មានវិហារកាតូលិកជាខ្មែរ មានតំណាងរាស្ត្រជាខ្មែរ តែមិនទាន់ចេះកសាងសហគមន៍ឱ្យមានកម្លាំងតាមរចនាសម្ព័ន្ធគំរូប្រជាធិបតេយ្យបាននៅឡើយទេ ម្ល៉ោះហើយមិនមានអ្នកឈរឈ្មោះឱ្យគេបោះឆ្នោតមាំទាំមិនចេញទៅបោះឆ្នោតមិនត្រៀមកសាងទីក្រុង ដើម្បីឱ្យទាញយកប្រយោជន៍សម្រាប់អនាគតភ្លឺស្វាងរបស់គ្រួសារខ្លួនក្នុងសហគមន៍ខ្លួនបន្តិចណាទេ ។ ដោយចាស់ៗមិនបានគិត ក៏បណ្តាលឱ្យយុវជនជំនាន់បន្តបន្ទាប់ ក៏មិនផ្តោតអារម្មណ៍ឱ្យបានខ្លាំងក្លាដូចគ្នាដែរ...,។ ឥឡូវដោយសារតែការប្តឹងផ្តល់ ក៏បាន"ផ្តល់ឱកាសដ៏ល្អកម្រមាន"ដល់សហគមន៍ខ្មែរហើយ តើ ប្រជាពលរដ្ឋខ្មែរនឹងប្រឹងប្រែងឱ្យមានតំណាងដ៏ពិតប្រាកដដល់ខ្មែរនៅឡូវែលដែរឬទេ?

ដើម្បីឱ្យក្រុងឡូវែលអាចមាន"តំណាងជាជនជាតិភាគតិច"បាន គឺគេចែកក្រុងជាសង្កាត់ចំនួន៩ ហើយ"សង្កាត់និមួយៗត្រូវមានដំណាងរបស់ខ្លួន" គេបានគិតថា"សង្កាត់ណាដែលមានជនជាតិភាគតិចរស់នៅច្រើននោះ" "ត្រូវឱ្យមានតំណាងជាជនជាតិភាគតិចនោះ"បើតាមកិច្ចព្រមព្រៀងគឺ"ត្រូវឱ្យមានតំណាងជនភាគតិច នៅក្នុងសង្កាត់យ៉ាងហោចណាស់ក៏២ក្នុងចំណោម៩"ដែរ ។

ចំណែកឯគណកម្មការសាលារៀនវិញ គេយល់ថា"ត្រូវមានចំនួន៦ ក្នុងនោះ៤នាក់ដំណាងឱ្យសង្កាត់ District ត្រូវចែកជា៤ ដែលយ៉ាងហោចណាស់ក៏មាន២អាសនៈ ត្រូវតែមកពីតំណាងសង្កាត់ជនជាតិភាគតិច ហើយ២អាសនៈទៀត ដែលនៅសល់ត្រូវដាក់ឱ្យ At large គឺបោះឆ្នោតជាសាកល" ។

យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះសន្យាថា "នឹងមានការស្នើរប្រជាមតិមួយ នាឱកាសបោះឆ្នោតខែកញ្ញាខាងមុខឱ្យប្រជាពលរដ្ឋជាអ្នកសម្រេចថាយកជម្រើសយកប្រព័ន្ធបោះឆ្នោតណាមួយសម្រាប់ឡូវែល ដែលខ្លួនពេញចិត្តជាងគេ..." ។

តទៅទំព័រទី ០៣


សាលាក្រុងឡូវែលនឹងប្តូររបៀបបោះឆ្នោតនៅឆ្នាំ២០២០




មណ្ឌលពិនិត្យសុខភាពឡូវែល

Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D. Chhan Touch, C.N.P.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

ជំងឺទូទៅ សុខភាពផ្លូវចិត្ត

Family Medicine & Behavioral Health



អាស័យដ្ឋាន

1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

តមកពីទំព័រទី ០២

## មានការវិវត្តន៍ថ្មីពីបណ្តឹងឱ្យប្តូរប្រព័ន្ធ...

លោកអ្នកជាម្ចាស់ឆ្នោតនឹងមានជម្រើសយ៉ាងហោចណាស់ក៏១ក្នុងចំណោមពាករណីដែរ ឆ្លើយតបនឹងប្រជាមតិនោះ... ប៉ុន្តែគេនៅចាំបានថា ក្រុមប្រឹក្សាក្រុងឡូវែលបច្ចុប្បន្ន គឺជាក្រុមដែលមានទំនោរទៅបំរើផលប្រយោជន៏របស់សង្កាត់ បែលវឺឌៀ យ៉ាងច្បាស់ក្រឡែត... ដូច្នេះសូមប្រជាពលរដ្ឋភាគតិចមានខ្មែរជាដើមនោះ ប្រើការប្រុងប្រយ័ត្នឱ្យខ្ពស់ បើមិនចង់បាត់ឱកាស"ដ៏កម្រ"សម្រាប់បំរើសហគមន៏ខ្លួនឯងពេលនេះទេ ទុកឱ្យក្រុមសង្កាត់ផ្សេងទាញយកចំណេញពីដៃខ្លួនឯងទៅបានឱ្យសោះ។

លោក វ៉តនី អេលីយ៉ុត សមាជិកក្រុមប្រឹក្សាក្រុងបានឱ្យដឹងថា នៅប្រជាបតិ គេនឹងដាក់សំនួរតែ២ករណីប៉ុណ្ណោះ ឱ្យជ្រើសយកណាមួយ គឺ ១-ខ្ញុំចង់បានករណីឱ្យមានដំណាងក្នុងសង្កាត់របស់ខ្ញុំ ២-ខ្ញុំចង់បានដំណាងតាមឋានានុក្រមក្នុងឡូវែល... យើងនឹងត្រឡប់មកមកសិក្សាពីជម្រើសនេះវិញ នៅពេលក្រោយ។

លោក អាដាម ព្រិល សកម្មជនសង្កាត់ ខាព័រស្ពែរ និយាយថា ប្រជាពលរដ្ឋខ្មែរត្រូវប្រជុំគ្នាជាប្រញាប់ ហើយនាំគ្នាសិក្សាជម្រើសនេះឱ្យបានច្បាស់លាស់ មុននឹងទៅបោះឆ្នោត ពីព្រោះមិនមាននរណាចង់ឱ្យយើងបានជឿនលឿនជាងសព្វថ្ងៃនេះទេ!



លោក អាដាម ព្រិល



លោក វ៉តនី អ៊ីលីយ៉ុត

កិច្ចព្រមព្រៀងនោះ ក៏មាននិយាយពីប្រាក់ចំណាយចំពោះមេធាវិដើមបណ្តឹង ដែលធ្វើការបំរើឱ្យអាមេរិកាំងជនជាតិភាគតិចនោះ គឺសាលាក្រុងនឹងចេញថ្លៃឈ្នួល២៨ម៉ឺនដុល្លារ គឺប្រាក់ពាក់កណ្តាលដំបូង គេយកនៅ២សប្តាហ៏ខាងមុខនេះ ហើយប្រាក់ពាក់កណ្តាលទៀតគេយកនៅមុនដំណាច់ឆ្នាំ។

## សមាគម"ASALEC" ជួយរកការងារឱ្យធ្វើ

នៅទីក្រុងឡូវែល នឹងតំបន់ជិតខាងមានការងារជាច្រើន កំពុងត្រូវការបុគ្គលិកធ្វើការខាង "ភោជនីយដ្ឋាន-ភេសជ្ជដ្ឋាន"អាមេរិកាំង - មានៈ អ្នកបំរើភេសជ្ជៈ អ្នកបំរើម្ហូបនឹងអ្នកចំអិនម្ហូប ។ បើលោកអ្នកចង់ធ្វើការនោះ ត្រូវមានសញ្ញាប័ត្រដែលអាចរៀនយកបានរយពេលខ្លី ហើយមានការធ្វើតែម្តង -គឺជាការងារដែលហ្នឹងហ្ន ហើយទទួលកំរៃខ្ពស់ ។

ព័តិមានបន្ថែម សូមទាក់ទងមក
ទូរស័ព្ទលេខ **978-942 1641**

## ឡូវែល-ជំនួយសិក្សាពេលវិសម្សកាល

នាឱកាសវិសម្សកាលខាងមុខនេះ លោកអ្នកចង់ឱ្យកូនទទួលការរៀនបន្ថែមនៅពេលដែលលោកអ្នកមានកុំព្យូទ័រនៅផ្ទះ លោកអ្នកមានកូនចៅរៀនពីថ្នាក់ទី១ ដល់ទី ១២ ហើយត្រូវការឱ្យមានការជួយបង្រៀនបន្ថែមលើកម្មវិធីសាលារៀនទាំងឡាយនោះ ។ សមាគម "អេសេឡិក"មានកម្មវិធី "IXL"តាមប្រព័ន្ធកុំព្យូទ័រ ស្របនឹងការបង្រៀននៅសាលាកូនចៅលោកអ្នក ដើម្បីឱ្យកូនចៅអាចរៀនបន្ថែមបាន តាមពេលវេលាដែលមាន ហើយមានគ្រូតាមដាននូវគ្រប់មេរៀន ដែលកូនអ្នករៀននៅសាលារបស់ពួកគេបាន ។



លោកអ្នកជាមាតាបីតានឹងទទួលបាននូវសេចក្តីរាយការជាលាយលក្ខអក្សរពីគ្រូដឹកនាំកម្មវិធីក្នុង១ខែ២ដង ដើម្បីឱ្យដឹងពីការជឿនលឿនរបស់កូនចៅលោកអ្នក។

តម្លៃសិក្សា៣០ដុល្លាក្នុង១ខែ។ ដំណឹងបន្ថែម សូមទូរស័ព្ទរកលេខ ៩៧៨-៩៤២ ១៦៤១។






# “គ្រោដូជោ” Grodojo មានបង្រៀនក្បាច់គុនដល់កុមារនឹងមនុស្សធំ

ដោយខ្មែរផុសស.រ.អា



ប៉ុណ្ណារ៉ូ បានទៅចូលរួមបញ្ចប់វគ្គសិក្សាក្បាច់គុនចិនបូរាណមួយនៅ"គ្រោដូជោ"នាវិហារដ៏ស្រស់ស្អាតមួយនៅជាប់នឹងសាលាក្រុងឡូវែល។ ដោយថ្ងៃនេះមានក្រុមមាតាបិតានឹងគ្រួសារប្រមាណ៥0នាក់ ទៅមើលការសំដែលបិទវគ្គសិក្សាមួយរបស់សិស្ស"គុន"ផង។

ជាផ្នែកមួយដ៏ចំឡែក ដែលថ្នាក់សិក្សានោះ មានការអប់រំ ចារឹកចរិយាសិស្សក្មេងៗឱ្យចេះគោរពគ្នាទៅវិញទៅមករៀនធ្វើបង្អែមបំប៉ងសុខភាពរៀន ដាំដំណាំអប់រំឱ្យចេះស្រឡាញ់បរិដ្ឋាននឹងហាត់ក្បាច់គុនដើម្បីតែសុខភាពរឹងមាំរបស់រាងកាយ... ដោយ "មាសស្ទ័រ ម៉ាយ"នឹងអ្នកជំនួយការ



យ៉ាងគ្រប់គ្រាន់ក្នុងទីធ្លាដ៏ធំទូលាយ។ ករណីនេះស្របនឹង




ការអប់រំកាយសម្បទានឹងចរឹករហ័សរហួនរបស់ ប៉ុណ្ណារ៉ូ ពេកណាស់ ពីព្រោះគេត្រូវការទប់ស្មារតីកុំឱ្យក្លាយទៅជាវលាមហួសហេតុ។

បិទវគ្គមែន បន្ទាប់ពីបើកទ្វាររយៈ ពេល៣ឆ្នាំ ហើយតែ"គ្រោដូជោ"មិនបានបិទទ្វារនាឱកាសវិស្សមកាលនេះទេ មាតាបិតាអាចទៅចុះឈ្មោះឱ្យកូនទៅសិក្សាយ៉ាងគួរឱ្យទុកចិត្តបាន។






មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
*Family Medicine*
សុខភាពផ្លូវចិត្ត
*Behavioral Health*
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# Rhode Island Capitol Police Launches Recruitment Campaign Seeking Highly Qualified and Diverse Applicants

By KhmerPost USA

Providence, Rhode Island — Colonel James M. Manni, Superintendent of the Rhode Island State Police and Director of the Department of Public Safety, announced the Capitol Police is launching a recruitment campaign for new Capitol Police Officers starting this week.

Capitol Police Chief Joseph T. Little Jr. said the goal is to find a large pool of highly qualified men and women who reflect the racial, ethnic and cultural diversity of the community. "We are seeking the best possible candidates with the experience, skills and commitment needed to serve as Capitol Police Officers," he said.

The Capitol Police, which falls under the Department of Public Safety, provides police services and general security for the State Capitol and other state agencies and buildings throughout the state. They are responsible for maintaining order, as well as providing for the safety, security and protection of employees, visitors and state property.

Capitol Police officers operate metal detectors and x-ray machines at the entrances to the State House, as well as at courthouses and other state buildings. They are responsible for screening employees and visitors, as well as preventing and detecting crimes and apprehending violators.



Applicants must meet the following requirements

- U.S. citizen, 18 years old of age, a high school graduate or possess a general equivalency diploma (GED),
- Possess and maintain a valid Rhode Island operator's driving license Meet Rhode Island qualifications to carry weapons used in the performance of duty

All applicants will be required to undergo a physical agility test, written examination, oral board interview, extensive background investigation, medical exam and psychological exam. Successful candidates will be admitted to the Capitol Police Training Academy, an eight-week program, where they will receive the education and training needed to serve as Capitol Police Officers.

Upon completion of the Training Academy, candidates will be chosen for appointment based on their final rankings in the recruitment pool, Chief Little said. Anyone not immediately chosen for appointment will be placed on a reserve list for future openings.

Applications are being accepted through July 26. Interested applicants must apply through the state recruitment website at www.apply.ri.gov. Article contributed by Laura Meade Kirk, Rhode Island Department of Public Safety.


COMMUNITY TEAM WORK

"កិច្ចប្រជុំក្រុមប្រឹក្សា"

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា"កុំមូនីធី ទីមវើក" បានត្រូវកំណត់នៅថ្ងៃពុធ ទី២៦ មិថុនា ២០១៩ វេលាល្ងាច ម៉ោង៧គត់

នៅ១៥៥ផ្លូវមេរីម៉ាក ជាន់ទី២ បន្ទប់"ម៉ាជូរី ម៉ាក់ឌ័រមូទ"- សាធារណជនសូមស្វាគមន៍

BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, June 26th, 2019 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.



RI Department of Labor and Training
Workforce Development Division
Business Workforce Center

State of Rhode Island
Department of Public Safety
Colonel James M. Manni, Director

## RHODE ISLAND CAPITOL POLICE
## 2019 RECRUITMENT
### *June 16 ~ July 26, 2019*

**Capitol Police Officer Job Description:** To protect and provide police services and general security to the State Capitol, annexes, properties adjacent state buildings, grounds, premises and designated state properties against the ordinary hazards of trespass, theft, fire and damage; to maintain order on the premises; to provide for the safety, security, and protection of the public, employees and property; and to do related work as required.

**Candidates must pass all phases of the recruitment process prior to appointment:**

- *Physical agility test*
- *Written examination*
- *Oral board interview*
- *Extensive law enforcement background investigation*
- *Medical examination*
- *Psychological examination*
- *Capitol Police Training Academy*

**Additional requirements prior to appointment:**

- Must have reached the age of eighteen (18) years of age to be admitted to the Training Academy. There is no maximum age of admission to the Training Academy.
- Meet the State of Rhode Island qualification requirements to carry weapons used in the performance of duty.
- Possess a valid Rhode Island Operator's Driving License.
- Have NO body piercings or tattoos that may be visible while in Department uniform. The use of flesh colored sleeve will be acceptable to conceal any tattoos that are visible from the upper arm to the wrist bone.

FOR A MORE COMPREHENSIVE OVERVIEW, VISIT
www.capitolpolice.ri.gov/recruitment
State of Rhode Island is an Equal Opportunity/Diversity Employer

TO APPLY PLEASE SUBMIT APPLICATION MATERIALS AT
WWW.APPLY.RI.GOV

Administrative Offices: 1511 Pontiac Avenue, Cranston, RI 02920
Equal Opportunity Employer-Auxiliary Aids and services available upon request to individuals with disabilities. TTY via RI Relay 711



**STATE OF RHODE ISLAND AND PROVIDENCE PLANTATIONS**
**CIVIL SERVICE EXAMINATION ANNOUNCEMENT**

**SOCIAL CASEWORKER #6296**
**Salary Range $48,063 – 55,415* (Pay Grade 22)**
**Examination Weight: 100 % Written**

**APPLICATION PERIOD: June 17, 2019 – July 26, 2019**

Employees in this classification perform social casework providing social service in one of these fields: public assistance, or child welfare, or soldiers' welfare, or in medical or psychiatric social work programs, or health or correctional programs and to work in collaboration with others as a member of a diagnostic or therapeutic team; and to do related work as required. Candidates must possess a Bachelor's Degree from an accredited institution of higher education with specialization in Sociology, or Psychology, Social Work or Child Development or Vocational Guidance. Or, any combination of education and experience that shall be substantially equivalent to the above education and experience.

For an application form and additional information on how to apply, please visit www.apply.ri.gov, call (401) 222-2160 (RI Relay: 711), or visit the Department of Administration Division of Human Resources, One Capitol Hill, 3rd Floor, Providence, RI.

*Wages are defined by applicable union contract.
AN EQUAL OPPORTUNITY/DIVERSITY EMPLOYER

"ទស្សនៈនយោបាយ

# នយោបាយកម្ពុជានៅគ្រប់ក្រឡាទាល់ច្រក

ដោយ ពិន សំខុន

មើលពីក្រៅទៅ នយោបាយកម្ពុជាកំពុងនៅត្រាំក្នុងទឹកក្ដៅអ៊ុនៗរបស់ចំហាយកុម្មុយនិស្ដចិន ដែលកំពុងត្រូវការឱ្យប្រទេសកម្ពុជាគាំទ្រខ្លួន ក្នុងដំណើរទៅរកការវាតទីឥទ្ធិពល"ផ្លូវសូត្រ"របស់ខ្លួន ក៏សាងខ្វាត់ខ្វែងនៅអាស៊ីនឹងនៅអឺរ៉ុបខាងកើត ជាមួយសមមិត្ររុស្ស៊ី ។ តែតាមពិតទៅ ថ្វីត្បិតតែសហរដ្ឋអាមេរិកបានប្ដូរនយោបាយក្រៅប្រទេសរបស់ខ្លួនក្ដី ឬក៏ថ្វីត្បិតតែសហភាពអឺរ៉ុបខិតខំពង្រឹងជំហ៊រដោយខ្លួនឯង ទប់ទល់នឹងការដកថយកម្លាំងនៃសហរដ្ឋអាមេរិកក្ដី មហាអំណាចទាំង២ មិនដែលលះបង់គោលការប្រជាធិបតេយ្យ គោរពសិទ្ធមនុស្ស នឹងមហិច្ឆិតាគ្រប់គ្រងពិភពលោកនោះទេ...ម្ល៉ោះហើយភាពក្រអឺតក្រទមរបស់លោក ហ៊ុន សែន នៅកម្ពុជាគាំទ្រដោយមហាមិត្រចិនដែលហាក់ដូចជាមានមហិទ្ធិរិទ្ធិនៅមហាសមុទ្រចិន រហូតដល់ឈូងសមុទ្រឥណ្ឌាទៀតផងនោះគឺគ្រាន់តែលាក់បំបាំងភាពទាល់ច្រកដ៏សំខាន់មួយដែលខ្លួនបានបោះជំហ៊ាន"ជាន់ផុក"ប្រឡាក់អស់ទៅហើយនោះទេ សង្ឃឹមថានឹងឆ្លងផុតឧបសគ្គរំដោះភាពទាល់ច្រកនោះបាន...។

តើហេតុអ្វីបានជាខ្ញុំហ៊ានអះអាងថា ចិនធ្វើនយោបាយទាល់ច្រកយ៉ាងនេះ?

សូមមើលបន្តិចទៅមើល ! កម្លាំងនៃប្រជាធិបតេយ្យ វាមានការលំបាកនឹងក៏សាងមែន នៅក្នុងប្រទេសដែលមិនបានជឿនោះ ជាការពិតហើយ! ក៏ប៉ុន្តែកាលណាគេមានជំនឿរាប់រយឆ្នាំលើកម្លាំងនោះ ដូចជាសហរដ្ឋអាមេរិក ដូចជាសហភាពអឺរ៉ុបជាដើម វាធ្វើឱ្យប្រទេសរឹងមាំ មិនអាចបាក់បែក ឬរលំទៅវិញបានទេ... ផ្ទុយទៅវិញ ប្រទេសចិន មិនបានជឿលើ"វណ្ណអធន" របស់ខ្លួន ដែលមានអាយុកាលមិនបាន៥០ឆ្នាំនោះទេ, សេដ្ឋកិច្ចក៏ពឹងលើកម្លាំងពលកម្មថោក។, លក់ឥវ៉ាន់មានគុណភាពធុនក្រោមឬមធ្យមលក់ដាច់ដោយបន្លំ ឬអនុគ្រោះពន្ធពិប្រទេសធំ, តើអាវុធលើនាវាពិឃាដ២-៣គ្រឿង ឬក៏មីសីលឆ្លងភពចិន ធ្វើឱ្យប្រទេសកូនសេដ្ឋី មានកូរ៉េខាងត្បូង ចិនតាយវ៉ាន់ នឹងជប៉ុនខ្លាចការគម្រាមរបស់ខ្លួនដែរឬទេ? ទំនងជាមិនបានខ្លាចនាគក្រដាសនោះទេ!... ពីព្រោះជាប្រទេសជឿនលឿនខ្លាំងណាស់, ការគម្រាមទាំងអម្បាមាណសុទ្ធតែសម្រាប់បំបាក់ស្មារតី ជាការសម្ដែងសៀកមិនខុសអ្វីពីការដែលគាត់បានបង្ហាត់ក្រុមខ្មែរក្រហមឱ្យចេះសម្លាប់ខ្មែរឱ្យរង្គាល ដោយធ្វើឱ្យខ្លាចបាក់ស្បាតនោះទេ! វាជាស្នៀតរបស់ពួកទាល់ច្រក សម្រាប់បំភាន់ភ្នែក វាគ្មានដំណោះស្រាយរុងរឿង ឬបើកច្រកសន្តិភាពសម្រាប់អ្នកខ្លាចនោះទេ ។


ប្រមុខរដ្ឋាភិបាលខ្មែរ និងចិន មិនជឿលើលទ្ធិប្រជាធិបតេយ្យ

ចំណែកឯប្រទេសកម្ពុជា ដែលដូចគ្នានឹងចិន មានរបបពុំបានជឿលើលទ្ធិកុម្មុយនិស្តរបស់ខ្លួន ហើយស្រាប់តែកំពុងប្ដូរទៅជារបបផ្ដាច់ការគ្រួសារនិយម, តើមានបទពិសោធន៍ឯណា សម្រាប់ទៅទប់ទល់កម្លាំងប្រជាធិបតេយ្យពិភពលោកបាននោះ, សព្វថ្ងៃនេះ ជាកម្លាំងជឿទុកចិត្តលើមហាអំណាចចិនសុទ្ធសាធ, ហ៊ុន សែនកំពុងតែជឿថា"អាមេរិកាំងជំពាក់លុយចិនរាប់មិនអស់ តែដល់អាមេរិកទារបំណុលពន្ធដាររាប់ពាន់លានដុល្លាពីចិន នៅពេលថ្មីៗនេះ ទើបដឹងថាចៅហ្វាយអញមិនបានសឿងដូចអញបានគិតនោះទេ!"។ ក្រុមឃ្លានលុយនឹងអំណាចជាងស្រឡាញ់ពលរដ្ឋខ្លួនឯង ដូចជាហ៊ុន សែន បានជ្រើសយកចិនឱ្យបំរើមហិច្ឆិតាខ្លួន បន្តពីសម្ដេចនរោត្តម សីហនុ ហើយប្ដូរដៃពី"អ៊ុនតាក់" តទៅទំព័រទី ០៧







តមកពីទំព័រទី ០៦

## នយោបាយកម្ពុជានៅគ្រប់ក្រឡា...

ដែលជាអំណាចប្រជាជាតិរឹងមាំនឹងយូរ អង្វែង ទៅយក"ខ្យល់ចិនដែលបក់ បានតែហើយ តែ ខ្យល់នោះ ដកដង្ហើមខ្លួនឯងមិនបានថែមទាំងវាស៊ីរូង ដល់ខួរឆ្អឹងគ្មានសែសសល់ក្រៅតែពី"សំបកជាខ្មែរដ៏ គាត់តែងមានដំណោះស្រាយជួយឃីតយោងលោក ហ៊ុន សែន ឱ្យរក្សាដំណែងជានាយករដ្ឋមន្ត្រីជាដ៏រាប ... ធ្វើទាល់តែបានគោរមងារថា"អ្នកស៊ីឈ្នួលចាញ់" ... ទើបគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា តេយ្យ ជាមួយបងប្អូនខ្មែររាប់លាននាក់ទៀតនៅ កម្ពុជា ដែលលើកទុងប្រឆាំងនឹងរបប ហ៊ុន សែន បំផ្លាញជាតិ ។

ដ៏រាបណាខ្មែរយើងមានដង្ហើមរស់នៅ អ្នកត្រូវ តែបន្តការតស៊ូដើម្បី"ខ្មែររស់" ប៉ុន្តែការតស៊ូនោះត្រូវ នៅបន្តជាមួយនឹងមេចលនាតស៊ូណា ដែលជាអ្នកកាន់ ឱ្យសោះ ។ ដូច្នេះចង់ឈ្នះក្រុមផ្តាច់ការ ហ៊ុន សែន ត្រូវតែចៀសវាងក្រុមតស៊ូគំរូចាស់ សម រង្ស៊ី ដែល កំពុងតែនាំអ្នកស្នេហាស្រឡាញ់ជាតិឱ្យវង្វេងផ្លូវ ទៅ ធ្លាក់អន្លង់ គាំងដំណើរទាល់ច្រក, នៅពេលដែលមាន ចលនាតស៊ូដ៏ធំណាមួយចេះរួបរួមគ្នាម្តងៗ ...ពីព្រោះ មេដឹកនាំនោះ ជាអ្នក"ស៊ីឈ្នួលសម្រាប់ចាញ់"ជា





អ្នកនយោបាយខ្មែរដែលស្តាប់ឱវាទលោក ហ៊ុន សែន តែងទទួលលទ្ធផលចាញ់ជាដរាប

គំរកជាទីបំផុត"នោះ... ហ្នឹងហើយជាលទ្ធផលនៃការ យកចិនជាមហាមិត្ររបស់ខ្មែរនោះ! ។

**ចុះកម្លាំងប្រជាធិបតេយ្យ ដែលបានចាប់បដិសន្ធិ នៅឆ្នាំ១៩៩៣ នៅកម្ពុជានោះ នៅឯណា?**

អង្គការសហប្រជាជាតិ( អ.ស.ប.)ជាកម្លាំង ប្រជាធិបតេយ្យបានចូលមកសង្គ្រោះខ្មែរ នាឆ្នាំ១៩៩៣ ដោយការបោះឆ្នោតសាកលដ៏ត្រឹមត្រូវមួយ, តែខ្មែរ បានពួតដៃគ្នាជាមួយសម្តេង សីហនុ ដើម្បី កំចាត់ អ.ស.ប. ដោយប្តូរលទ្ធផលឆ្នោតអ.ស.ប. ពី "ហ៊្វុនស៊ីនប៉ិចឈ្នះ ទៅជាស្មើគ្នានឹងគណបក្សប្រជាជន" ...ការស្មើគ្នានេះ បានផ្តល់ឱកាសដល់ ហ៊ុន សែន នៃ គណបក្សប្រជាជនឡើងកាន់ដំណែងជានាយករដ្ឋមន្ត្រី ហើយកំចាត់មនុស្សខ្លាំង ដែលបានចូលស្រុកជាបន្ត បន្ទាប់មានទ្រង់នរោត្តម រណឫទ្ធិ នឹងកម្លាំងរបស់ព្រះ អង្គអស់រាប់ពាន់នាក់ ។នេះជាការវង្វេងផ្លូវដ៏អស្ចារ្យ មួយទៅហើយសម្រាប់កម្ពុជានៅសល់រដ្ឋធម្មនុញ្ញ មួយទៀតដែរ ដែលគាត់តែងដោយ"អ៊ុនតាក់" ដែល អាចការពារគណបក្សភាគតិចនៅរដ្ឋសភាបាន ស្រាប់ តែមេបក្សប្រឆាំង សម រង្ស៊ី បានយល់ព្រមនឹង ហ៊ុន សែន អនុម័ទឱ្យកែរមាត្រា ពី២ភាគ៣ ទៅ ៥០% ព្រោះតែចង់បានធ្វើជា "ឪ"របស់គណបក្សប្រជាជន ម្ល៉ោះហើយ បន្តិចក្រោយមក គេក៏កំចាត់បានទាំងខ្លួន ឯងជាឪនោះ ដូច"អាគាំងគមាស្វូរ"ដូច្នោះដែរ ។ ចាប់ តាំងពីពេលនោះមក មេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី នោះ បានខិតខំប្រឹងទាញយកដំណែងជាមេបក្ស ប្រឆាំងដ៏មានប្រជាប្រិយ ប្រមូលប្រជាពលរដ្ឋ កម្មករ កសិករ ឱ្យមកតវ៉ា ធ្វើបាតុកម្មទាមទារទម្លាក់ ហ៊ុន សែន... មិនឈប់ឈរនៅក្នុងផ្លូវដែលខ្លួនវង្វេងគ្មាន ច្រកចេញ គឺរាល់ពេលដែលលោក ហ៊ុន សែន ទាល់ តម្រិះរៀបនឹងរលំលោក សម រង្ស៊ី នឹងគណបក្សរបស់ លេចមុខឡើង ។

ទៅរួមគ្នាជាមួយគណបក្សប្រឆាំងចុងក្រោយ នេះ ពីព្រោះតែមានជំនឿទៅលើសម្ព័ន្ធភាពនៃបក្ស ប្រឆាំងជាបក្សប្រជាធិបតេយ្យ ទើបយកឈ្នះលើ ហ៊ុន សែន បាន, តែទៅរួមដៃគ្នាជាមួយគណបក្ស លោក សម រង្ស៊ី ដែលជឿតែទៅលើខ្លួន ហើយមិន ហ៊ានគិតឱ្យគណបក្សណាខិតលើខ្លួន ឬឱ្យនរណាដណ្តើម យកងារជា"បក្សប្រឆាំងផ្តាច់មុខ"បានទេ... ពីព្រោះ វាជា"ប៊ីសនីស" លែងជានយោបាយតទៅទៀត ហើយ ។ ជោកជ័យនៃសម្ព័ន្ធភាពបក្ស"ភ្លើងទៀន" របស់ សម រង្ស៊ី នឹង"ព្រះអាទិត្យ"របស់ កឹម សុខា ជា"គណបក្សសង្គ្រោះជាតិ"តែមួយ បានផ្តល់លទ្ធផល ត្រចះត្រចង់មែន កាលពីឆ្នាំ២០១៣ ដោយប្រជាពល រដ្ឋចង់ឱ្យ"មានការផ្លាស់ប្តូររបប", ប៉ុន្តែ ហ៊ុន សែន មិនចង់ប្រគល់ជ័យជំនះឱ្យសង្គ្រោះជាតិទេ ទោះជា អ្នកឯងឈ្នះក៏ដោយ ដោយគាត់ជឿលើកម្លាំងកង ទ័ពរបស់គាត់, ស្របគ្នានឹងខាងសង្គ្រោះជាតិ ដែលមាន កម្លាំងការរាំរែកមិនបានត្រៀមខ្លួនយកឈ្នះជាផ្តាច់ ព្រាត់ ដោយប្រើកម្លាំងប្រជាពលរដ្ឋរាំលាននាក់ ដែលចេញមកទទួលជ័យជំនះរបស់គេផងនោះ... ក៏ មេដឹកនាំបក្សសង្គ្រោះជាតិ បែរជាជ្រើសយក "លទ្ធ ផលឆ្នោតចាញ់" ដោយគ្មានការឆែកឆេរត្រួតពិនិត្យ សើរើថែមទាំងនាំគ្នាគេចចេញពីប្រទេសខ្មែរអស់... ទុកឱកាសឱ្យហ៊ុនសែនវាយដៃកគោលពន្លិចសង្គ្រោះ ជាតិជាចុងបញ្ចប់តែម្តង...!

**ចុះឥឡូវនេះ ហួសពេលហើយឬនៅ?**

ថ្មីៗនេះ យើងមានយុវជនពលករខ្មែររាប់លាន នាក់ នៅកូរ៉េខាងត្បូង នៅជប៉ុន នៅប្រទេសថៃ ដោយ យើងមិននិយាយពីខ្មែរនៅអាមេរិក នៅកាណាដា នៅអឺរ៉ុប រាប់លាននាក់ទៀត ដែលនៅខាងប្រជាធិប ទង់ប្រជាធិបតេយ្យ អ្នកនោះត្រូវតែបរិសុទ្ធ មិនត្រូវ ឱ្យមានបន្ទិលសង្ស័យ ឬខ្វះសិលធម៌"ឈិនឆៃ"សិន មិនបានជាដាច់ខាត់ ។ អ្នកមានកំហុសអតីតកាល ហើយបណ្តាលឱ្យចាញ់ជនផ្តាច់ការ ត្រូវតែយកជាមេ រៀនសម្រាប់ការតស៊ូទៅអនាគត កុំឱ្យជាន់ដានចាស់ យូរបន្តិចមកហើយ ។

អ្នកប្រជាធិបតេយ្យនឹងឈ្នះ នៅពេលណាដែល យើងមានជំហ៊ារច្បាស់លាស់ ចំពោះជាតិមិនមែងយើង ឈ្នះដោយសារនៅជាមួយនឹង"អ្នកចាក់ខ្សែ"នោះទេ ។






# សម រង្ស៊ី នឹងត្រឡប់ទៅកម្ពុជាវិញនៅខែកញ្ញាខាងមុខ

ម្តងនេះទំនងជាមានការពិតច្រើន នៅពេលដែលលោក សម រង្ស៊ី សន្យាសារជាថ្មីថា"នឹងត្រឡប់ទៅកម្ពុជាវិញ ក្នុងខែកញ្ញាឆ្នាំ២០១៩ខាងមុខ បន្ទាប់



ពីគណកម្មការចំពោះកិច្ចរបស់គណបក្សសង្គ្រោះជាតិ បានចេញសេចក្តីសម្រេចចិត្ត កាលពីថ្ងៃសុក្រ ទី៨ ខែមិថុនាមុន នៅ"មីនីសូតា"ឱ្យប្រធានស្តីទីរបស់គេ ត្រឡប់ទៅកម្ពុជាវិញ ឱ្យបានមុនដំណាច់ឆ្នាំ២០១៩ នេះបើស្តាប់តាមសម្តីលោកអតីតតំណាងរាស្ត្រ អ៊ុំ សំអាន នៅវិទ្យុអាស៊ីសេរី។

ពុំមាននរណាដឹងពីគម្រោងច្បាស់លាស់របស់លោក សម រង្ស៊ី ថានឹងធ្វើអ្វី នៅមុនពេលចេញដំណើរនឹងនៅពេលទៅដល់កម្ពុជានៅឡើយទេ ក្រៅតែពីឮថា"ទៅដឹកនាំប្រជារាស្ត្រទម្លាក់ លោក ហ៊ុន សែន..." ក៏ប៉ុន្តែពីរដ្ឋាភិបាលភ្នំពេញវិញ គេបានប្រាប់ឱ្យដឹងរួចហើយ ពីការត្រៀមចាប់ខ្លួនលោក សម រង្ស៊ី យកទៅដាក់ពន្ធនាគារ តទៅទំព័រទី១១

# ប្រទេសថៃ: ប្រាយុទ្ធ ចាន់អូចារ បានទទួលការតែងតាំងនាយករដ្ឋមន្ត្រីអាណត្តិថ្មី

ព្រះមហាក្សត្រថៃថ្មី ព្រះមហាវិជ្ជាឡុងកន ទើបនឹងបានតែងតាំង នាយករដ្ឋមន្ត្រីថ្មី ប្រាយុទ្ធ ចាន់អូចារមកពីគណបក្សយោធានិយម"ប្រាឡាង ប្រាឆារ៉ាត" កាលពីថ្ងៃទី១១ មិថុនា បន្តដំណែងឱ្យនាយករដ្ឋមន្ត្រីចាស់ជាមនុស្សដដែល ដែលបានឡើង កាន់អំណាចកាលពីឆ្នាំ២០១៤ ដោយរដ្ឋប្រហារយោធា។ មុខដំណែងលើកនេះ គឺចេញពីការបោះឆ្នោតសាលក តាមរដ្ឋធម្មនុញ្ញថ្មី ហើយមានគណបក្សចំនួន៧៦ចូលរួម ក្នុងនោះក៏មានគណបក្ស"ភឿថៃ" គាំទ្រដោយនាយករដ្ឋមន្ត្រីចាស់ ថាក់ស៊ីន ស៊ីណាវ៉ាត្រា ដែលរងការទម្លាក់ពីដំណែង ហើយត្រូវនិរទេសចេញពីប្រទេសថៃថែមទៀតផង។

ក្នុងរយៈពេល៥ឆ្នាំ ដែលក្រុមយោធាកាន់កាប់ប្រទេសថៃដោយកម្លាំងរដ្ឋប្រហារក្រុមនោះបានកែប្រែរដ្ឋធម្មនុញ្ញ ហើយបង្កើតសភាជាន់ជាន់ទាបមាន៥០០អាសនៈដោយការបោះឆ្នោតសាកល ក៏ប៉ុន្តែសម្រាប់ សភាជាន់ខ្ពស់ តទៅទំព័រទី ១១




រូបភាពបេក្ខជននាយករដ្ឋមន្ត្រីថៃ


THE LRTA INTRODUCES
NEW SUNDAY SERVICE
9 MONTH PILOT PROGRAM
EFFECTIVE JUNE 16, 2019

The LRTA strives to provide our valued customers with the best possible service. We are proud to provide 10 Bus Routes on Sundays.




Route 2
Belvidere

Route 5
Westford Street/Drum Hill

Route 7
Pawtucketville/UMass North

Route 10
Dracut/Tyngsboro

Route 12
Tewksbury via Rte. 38

Route 13
Billerica via Edson

Route 14
Burlington Mall/Lahey Clinic

New Combination Route 15 & 16
Chelmsford/Westford via Rtes. 129 & 110 and Chelmsford via Chelmsford Street

Route 18
Downtown Shuttle

Lowell Regional Transit Authority

BUS INFORMATION: 978-452-6161 • WWW.LRTA.COM


Ashok Joshi, M.D.


Prema Daniel, NP


Julie Gallagher, FNP


Chantrea Yim-Bo
Office Coordinator

C.B.C Medical & Walk In Center Primary Care
មជ្ឈមណ្ឌលព្យាបាលជំងឺបន្ទាន់ C.B.C សេវាថែទាំសុខភាពជាប្រចាំ

*Serving Lowell Community for 25 Years* បំរើសហគមន៍ឡូវែលអស់រយៈពេល 25 ឆ្នាំ

***Accepting New Patients***
***Accepting ALL Insurances***

- In House Lab Services
- Immunizations & Injections
- PT1 Transportation Available
- Treatment for Diabetes and Hypertension
- Physical Exams
- Emergency Room & Inpatient Hospital Follow Ups
- Wellness & Preventative Care
- Workers Comp Medical Treatment
- DOT Physicals
- Walk-In for Illness and Minor Injury

**ទទួលយកអ្នកជម្ងឺថ្មី**
**ទទួលយកគ្រប់ធានារ៉ាប់រងទាំងអស់**

* សេវាវិភាគវេជ្ជសាស្ត្រនៅនឹងកន្លែង
* ការចាក់ថ្នាំបង្ការរោគ & ថ្នាំវ៉ាក់សាំង
* មានរថយន្តសម្រាប់ធ្វើដំណើរមកដល់កន្លែងសម្រាប់ម៉ាសហិល
* ព្យាបាលជំងឺទឹកនោមផ្អែម និងលើសឈាម
* ការវិភាគរាងកាយ
* ការតាមដានអ្នកជំងឺដែលត្រូវការស្នាក់នៅមន្ទីពេទ្យ និងការសង្គ្រោះបន្ទាន់
* ការថែទាំដើម្បីការពារ និងរក្សាសុភាព
* ការព្យាបាលក្រោមការធានារ៉ាប់រងគ្រោះថ្នាក់ចំពោះនិយោជិក
* ការពិនិត្យរាងកាយសម្រាប់សុំប័ណ្ណបើកបរ
* អ្នកមានជំងឺ និងរងរបួសតិចតួចមិនចាំបាច់មានការណាត់ជាមុន

Our Staff Speaks Khmer and Spanish! **បុគ្គលិករបស់យើងនិយាយភាសាខ្មែរ និងស្ពេនីស**

***Affiliated with Lowell General for Complete Connected Care***
សហការណ៍ជាមួយមន្ទីរពេទ្យ ឡូ យ៉ែនន័រល ដើម្បីទទួលបានការថែរក្សារឲ្យបានពេញលេញ

16 Pine Street, Unit #5 • Lowell, MA
Tel: 978-454-9703 • Fax: 978-528-2024 ទូរសព្ទ័លេខ: 978-454-9703
Open Hours: 8am - 4pm • Monday - Friday ម៉ោងធ្វើការ: 8 am – 4 pm ថ្ងៃច័ន្ទ - សុក្រ


# ល្បីពេញស្រុកខ្មែរ!! កុំភ្លេចស្លឹកប្រម៉ាត់ខ្លាឃ្មុំ
## ពិសាររាល់ថ្ងៃអ្នកនឹងដឹងពីប្រសិទ្ធភាពសម្រាប់
## អ្នកមានជំងឺលើសឈាម ទឹកនោមផ្អែម មហារីក ក្រពះរ៉ាំរ៉ៃ





រាល់ថ្ងៃមានបងប្អូនជាច្រើន មានបញ្ហា ជំងឺក្រពះ ជំងឺលើសឈាម ទឹកនោមផ្អែម មហារីក និងជំងឺផ្សេងៗទៀត សូមកុំភ្លេចពិសារស្លឹកប្រម៉ាត់ខ្លាឃ្មុំពិតជាមានឱសថសក្ដិសិទ្ធ ។បើសិនជាបងប្អូនអាចហូបបានជាប្រចាំពិតជាល្អណាស់ ព្រោះថ្នាំនេះជាឱសថសក្ដិសិទ្ធ ។ បើចង់ដឹងថាពិតអត់ញ៉ាំទាំងអស់គ្នាទៅ:

អត្ថប្រយោជន៍ថ្មីនៃស្លឹកប្រម៉ាត់ខ្លាឃ្មុំ វាមិនគ្រាន់តែត្រូវនិង ជំងឺលើសឈាម ទឹកនោមផ្អែម មហារីក ស្លេសក្នុងបំពង់កជំងឺមហារីកដោះ ជំងឺឬសដូងបាត ក្រពះ ពោះវៀនជាប្រចាំទេ វាថែមទាំងត្រូវជំងឺគ្រុសក្នុងតម្រងនោមថែមទៀតផង និងអ្នកឈឺចុកពោះ ចុកក្រពះរ៉ាំរ៉ៃ ត្រូវទាំងអស់ ។

## វិធីប្រើ:

១-សម្រាប់អ្នកទ្រាំរសជាតិល្វីងបានបេះស្លឹកវាលាងឱ្យស្អាត ព្រឹក២ ល្ងាច២សន្លឹក ទំពារញ៉ាំជាមួយទឹក (បើស្លឹកធំព្រឹក១សន្លឹក ល្ងាច១សន្លឹកបានហើយ) ។

២-យកស្លឹកវាបុកឱ្យម៉ត់លាយជាមួយទឹកដូងលៃឱ្យល្មមផឹក កុំឱ្យល្វីងជ្រុលផឹកកន្លះពែង ព្រឹកល្ងាច ។

៣-យកស្លឹកនិងមែកតូចៗហាលឱ្យស្ងួត រួចយកដាំទឹកផឹក ។សូមជួយចែកចាយបន្តរផង ឱ្យបងប្អូនមិត្តភក្តិយើងបានដឹងផង សូមអរគុណ ។ ប្រភព: កូន ខ្លាតូច ។



កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ
AccuCare
Home Care Agency
Group Adults Foster Care Program
ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅ ជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។
At no Cost to you
សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិក ខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide
បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ
ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
• រស់នៅផ្ទះរដ្ឋ
• អាយុ ២២ ឆ្នាំឡើងទៅ
• មានសំបុត្រពេទ្យ MassHealth
ផលប្រយោជន៍ទទួលបាន :
• ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
• ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
• ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសម៉ានីជើ
• វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
• សមាជិកអាចទាក់ទងមក២៤ម៉ោង
To be eligibled for GAFC you must:
• live in subsidized or public housing
• age 22 years and older
• eligible for Masshealth Standard
Benefits you will get:
• personal care service in your home,
• Medication Managemant
• an individual care plan developed by a registered nurse and case manager
• ongoing monitoring of needs
• 24-hour access to services
ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ០៨

## សម រង្ស៊ី នឹងត្រឡប់ទៅកម្ពុជាវិញ...

នៅពេលទៅដល់កម្ពុជាភ្លាម នោះ។

ការសម្រេចត្រឡប់ធ្វើមាតុភូមិនិវត្តន៍ ក្នុងរូបភាពទៅទម្លាក់លោក ហ៊ុន សែន ពេលនេះ ក្រុមលោក សម រង្ស៊ី នៅខ្វះកម្លាំងក្រុមម្ខាងទៀត ដែលធ្លាប់តែជាដៃគូរប្រយុទ្ធរបស់គណបក្សសង្គ្រោះជាតិ គឺខាងក្រុមលោក កឹម សុខា ដែលលោក សម រង្ស៊ី បាន ទៅបំបែកឱ្យខ្ចាត់ខ្ចាយ នៅគ្រប់ទីកន្លែងអស់ទៅហើយ, តែនោះទំនងជាលោកមិនមានការខ្វល់ខ្វាយពីការខ្វះកម្លាំងថាមពលអ្វីនោះទេ ពីព្រោះក្រុមលោកក៏ជាអ្នកបានធ្វើឱ្យបែកបាក់ មិនដឹងដោយចេតនាប្រការណាមួយនោះទេ គេអាចទាយបានថា "ឡូវែល នឹងទៅតាមលោកបានចំនួនតិចតួចណាស់" ទាំងចំនួនមនុស្សទាំងស្រោមសំបុត្រ -តែលោកនៅតែអាចទៅបញ្ចុះបញ្ចូល យុវពលករនៅកូរ៉េ -នៅជប៉ុន( គេមិនបានឃើញមុខលោកស្រែកជ័យឃោសនីដាក់លោក ហ៊ុន សែន នៅទីនោះទេ) - នៅប្រទេសថៃ - ចំណែកឯនៅកម្ពុជាលោកឱ្យអាចនឹងដើរហើរទៅបញ្ចុះបញ្ចូលអ្នកស្រុក អ្នកភូមិ បើសិនជាលោកមានសេរីភាពនៅទីនោះ...។

នៅពេលនេះ គេក៏ពុំទាន់ដឹងពីប្រតិកម្មសហគមន៍អន្តរជាតិខាងលោកសេរី ចំពោះមាតុភូមិនិវត្តន៍របស់លោកនៅឡើយទេ តែដោយសារលោកបានលេង កំផ្លែងដាក់គេច្រើនដងេក ដោយចេះតែទៅជួយយកអាសារ "ហ៊ុន សែន ធ្លាក់ទឹក! ហៃអើ! ហៃអើ! ឱ្យចេះតែរួចខ្លួនបាន" ម្ល៉ោះហើយ គេអាចទុកឱ្យ "ហ៊ុន សែន ចាប់លោក រង្ស៊ី ដាក់គុកសិន សិមគេ ស្រែកតវ៉ាជួយរំដោះលោកជាក្រោយ..."។

តមកពីទំព័រទី ០៨

## ប្រាយុទ្ធ ចាន់អូរចារ បានទទួល...

គឺព្រឹទ្ធសភាមាន២៥០អាសនៈ បង្កើតដោយការតែងតាំងពី "ក្រុមប្រឹក្សាកងទ័ព" ទាំងមូល។ រចនាសម្ព័ន្ធរបៀបនេះ បានផ្តល់ផលចំណេញដល់ការ តែងតាំងលោក ប្រាយុទ្ធ ចាន់អូចារ ជានាយករដ្ឋមន្ត្រីជាងបេក្ខជនឯទៀតៗទាំងអស់ ដែលជាហេតុធ្វើឱ្យមានការទិទានថា "ជាប្រព័ន្ធមិនស្មើរភាពគ្នាតាមលទ្ធិប្រជាធិបតេយ្យទេ"។

ថ្វីត្បិតតែមានអំណាចធំធេង តែលទ្ធផលនៃកាបោះឆ្នោតបានបញ្ជាក់ថាៈ គណបក្សយោធានិយម "ប្រឡាំងប្រឆាំាត" នេះ មិនសូវមានប្រជាប្រិយភាពប៉ុន្មានទេ ដោយសារបានចំនួនអាសននៅសភាដំណាងរាស្ត្រនៅលំដាប់ថ្នាក់លេខ២ បន្ទាប់ពីគណបក្ស "ភឿថៃ" គាំទ្រដោយលោកអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណេវ៉ាត្រា ហើយម្យ៉ាងទៀតក៏មិនមានគណបក្សនាផ្សេង ចង់ចងសម្ព័ន្ធចូលរួមជារដ្ឋាភិបាល ចម្រុះជាមួយគណបក្សយោធានោះទេ។ លោក ប្រា យុទ្ធ មានពេល១ខែសម្រាប់រៀបចំគណរដ្ឋមន្ត្រីថ្មី ដែលយើងនឹងត្រឡប់មករាយការវិញនៅពេលក្រោយទៀត។


សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អ KhmerPost USA

## Now Coming to California!

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service







# ដំណឹងល្អសម្រាប់លោកអ្នកដែលមាន បំណងចង់ជួសជុល និងកែលំអរផ្ទះ

ដោយខ្មែរផុស ស.រ.អា

ឡូវែល, ម៉ាសាជូសេតៈ សាលាក្រុងឡូវែល បាន កំពុងអនុវត្តន៏គម្រោងមួយដែលមានឈ្មោះថា កម្មវិធីកែលំអរលំនៅដ្ឋាន (City of Lowell Rehabilitation Program) នៅក្នុងគោលបំណងដើម្បីជួយពលរដ្ឋក្នុងការជួសជុល និងកែលំអរផ្ទះ ដូចជា ការកែលំអរប្រព័ន្ធភ្លើង, ប្រព័ន្ធទឹក និងកំដៅ,កែលំអរផ្ទះបាយ និងបន្ទប់ទឹក, ធ្វើដំបូលថ្មី, រៀបការរ៉ូ និងអ្វីៗជាច្រើនទៀត ដើម្បីជួយធ្វើឱ្យប្រសើរឡើងនូវក៏រិតជីវភាព និងគុណភាពនៃជីវិតចំពោះក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យម។



Merrimack Valley Housing Partnership team from left to right: Ed Alcantara, Cathy Mercado, and Jim Wild

នៅក្នុងគម្រោងនេះ លោកអ្នកនឹងទទួលបានកម្ចីពីសាលាក្រុងឡូវែលដោយមិនមានការប្រាក់ ដើម្បីយកមកធ្វើការជួសជុលកំលែអរផ្ទះរបស់លោកអ្នក។ ប៉ុន្តែលោកអ្នកត្រូវធ្វើការទូទាត់សងវិញនៅពេលលក់ផ្ទះ, ការស្នើឥណទានសាជាថ្មី, រឺការផ្ទេរកម្មសិទ្ធផ្ទះ។ លោកអ្នកអាចយកប្រាក់ដែលខ្ចីទៅធ្វើផ្ទះ ហើយមិនទាន់បង់រហូតដល់ពេលលោកអ្នកលក់ផ្ទះក្នុងកំឡុង ៥ ឆ្នាំ, ១០ ឆ្នាំ, ២០ ឆ្នាំ រឺក៏យូរជាងនេះ។ វិធីម៉្យាងទៀត លោកអ្នកអាចសង់ទាំងអស់តែម្តងនៅពេលណាក៏បានដោយមិនមានការផាកពិន័យនោះទេ។

លក្ខខ័ណ្ឌដើម្បីទទួលបានគម្រោងជំនួយនេះ គឺទាក់ទងនឹងប្រាក់ចំណូលប្រចាំឆ្នាំរបស់ម្ចាស់ផ្ទះម្នាក់។ ម្ចាស់ផ្ទះដែលមានសមាជិកតែម្នាក់ ត្រូវមានប្រាក់ចំណូលចាប់ពី $50,350 ក្នុងមួយឆ្នាំ ហើយរហូតដល់ $94,950 សម្រាប់ម្ចាស់ផ្ទះដែលមានសមាជិកគ្រួសារ ៨នាក់ គឺអាចដាក់ពាក្យស្នើរសុំគម្រោងជំនួយនេះបាន។ បន្ថែមទៅនឹងការក៏រិតនៃប្រាក់ចំណូលម្ចាស់ផ្ទះនិមួយៗត្រូវធ្វើជាម្ចាស់លើអចលទ្រព្យយ៉ាងហោចណាស់ឱ្យបាន៣ឆ្នាំ ហើយស្នាក់នៅក្នុងផ្ទះនោះផងដែរ។

ជានេះទៅទៀត កម្មសិទ្ធិផ្ទះមិនត្រូវជាប់ទាក់ទងនឹងអ្នកណាផ្សេង ហើយរាល់ពន្ធ និងវិក្កយបត្រទឹកភ្លើកត្រូវតែដោយថ្មីៗដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យ។ ប្រសិនបើផ្ទះសាងសង់មុនឆ្នាំ ១៩៧៨ ចំចាប់ត្រូវមានលិខិតបញ្ជាក់ពីការអនុលោមនតាមគោលការណ៏របស់រដ្ឋ និងសហព័ន្ធពីការប្រើប្រាស់ថ្នាំលាបមិនប៉ះពាល់ដល់សុខភាព។

ចំនួនទឹកប្រាក់ដែលលោកអាចទទួលបានពីគម្រោងក្នុងការកែលំអរផ្ទះ គឺវាអាស្រ័យលើតម្លៃផ្ទះ, ចំនួនប្រាក់កម្ចីដើម្បីទិញផ្ទះ និងអ្វីដែលម្ចាស់ផ្ទះត្រូវការដើម្បីធ្វើឱ្យអចលនទ្រព្យមានសុវត្ថិភាព។ ទឹកប្រាក់ដែលទទួលបាននេះ មិនត្រូវបានផ្តល់ដោយផ្ទាល់ដល់ម្ចាស់ផ្ទះនោះទេ តែប្រាក់នេះ ត្រូវយកទៅចំណាយលើគម្រោងការជួលជុល នឹងកែលំអររបស់ម្ចាស់ផ្ទះដោយសាលាក្រុង ព្រោះថាមុននឹងទទួលបានប្រាក់ម្ចាស់ផ្ទះត្រូវរកក្រុមហ៊ុនមកធ្វើការប៉ានប្រមាណការចំណាយក្នុងការជួសជុល រួចសសេរសំណើរនៃគម្រោងចំណាយជួសជុលដាក់មកសាលាក្រុង។ បន្ទាប់មកសាលាក្រុង នឹងធ្វើការដាក់ដេញថ្លៃ និងជ្រើសរើសគម្រោងរបស់ក្រុមហ៊ុនណាដែលចំណាយតិចជាងគេដើម្បីមកធ្វើការជួសផុលផ្ទះរបស់លោកអ្នក។ នៅពេលការជួសជុលបញ្ចប់សាលាក្រុងនឹងចុះមកពិនិត្យមើលការងារជួសជុល ហើយម្ចាស់ផ្ទះ និងក្រុមហ៊ុនត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់ការសាងសង់។

ប្រសិនបើលោកអ្នកចាប់អារម្មណ៏ចំពោះគម្រោងនេះ សូមទាក់ទងទៅកាន់អង្គការ Ed Alcantara of Merrimack Valley Housing Partnership ដើម្បីទទួលបានព័តិមានបន្ថែម និងការដាក់ពាក្យតាមរយៈអ៊ីម៉េល និងលេខទូរស័ព្ទលេខ Ed@mvhp.org b¤ 978-459-8490។

KhmerPost USA, LLC
សារព័ត៏មានខ្មែរផុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us



និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us



Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy
ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

LEGEND
MOTOR GROUP, INC.
ហាងជួលជុលរថយន្ត លេជេន
មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?
ទូរស័ព្ទ 978-458-2085
COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។
115 Rock St. Unt #7 Lowell, MA 01854

# Explore Spring in the Greater Merrimack Valley

Just a half-hour drive northwest of Boston lies the Greater Merrimack Valley. The changing seasons add to the vibrancy of the region.

There is an undeniable spirit in the Greater Merrimack Valley – the same spirit that gave birth to our country. Each of our 21 towns and cities has its own unique charm and itinerary you need.

Your next adventure awaits you here!


















Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

merrimackvalley.org

Follow us on Twitter and Instagram @MerrimackValley



## ការបើកសម្ពោធឡើងវិញនៅថ្ងៃទី ១ ខែមិនា ខាងមុខនេះ

សូមមកធ្វើការណាត់ជួបជាមុននៅពេលឥឡូវនេះ

ហើយទទួលបានឧបករណ៍ធ្វើឲ្យធ្មេញសដោយមិនគិតថ្លៃ

យើងនិយាយភាសាខ្មែរ

ទទួលយកធានារ៉ាប់រងពីក្រុមហ៊ុនធំ និងរដ្ឋ

## ពេទ្យធ្មេញ

**Dracut Family Dental**
14 Loon Hill Road • Dracut, MA 01826
978-955-9005
dracutdental@gmail.com



DRACUT FAMILY
DENTAL

TOP DENTISTS 2018
AWARDED BY BOSTON MAGAZINE




# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រឺការមើលការខុសត្រូវក្នុងកំឡុងពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្មុគស្មាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺ ឱ្យមានអ្នកមកមើលថែអ្នកដែលជាស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយវ៉ើរស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការការទាក់ទងនឹងមនុស្សឯទៀត. រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នកដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប. ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្វាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌលថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នក មិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរា បង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទួលបានបទពិសោធន៍ថ្មី ទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្រ្ត។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ និងចំណីបំប៉នច្រើន
- ថ្នាក់កីឡាជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ
- ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពយ៉ាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា ខាងជ**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពីនីស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលផង

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ផ្ទាល់ខ្លួន
- ទទួលយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស. ស្ពេនទីស. ខ្មែរ. ឡាវ. ម៉ោង. ប៉ទុយក្កាល់. សូវៀត និងតាហ្គាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រងមេឌីឃេត សម្រាប់សេវាថាទាំចាស់ជរា លោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។

# គ្មានសហបង់ថ្លៃ — ជារៀងរហូត

គ្មានការបង់ថ្លៃសម្រាប់ការណាត់ជួបវេជ្ជបណ្ឌិត | គ្មានការបង់ថ្លៃសម្រាប់ការថែទាំធ្មេញ | គ្មានការបង់ថ្លៃសម្រាប់សេវាថែទាំភ្នែក

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth ទាំងអស់របស់ពួកគេ រួមទាំងការធានារ៉ាប់រងលើឱសថមានវេជ្ជបញ្ជា Part D។ លើសពីនេះ យើងបន្ថែមច្រើនទៀតដូចជា៖

- ប័ណ្ណអ្នកមានសុខភាពល្អ (Healthy You Card) ដើម្បីទិញថ្នាំគ្មានវេជ្ជបញ្ជា និងទំនិញទាក់ទងនឹងសុខភាពមួយចំនួន *(អ្នកទទួលបាន $100 ក្នុងមួយឆមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំសុខភាពដែលសម្របសម្រួលការមើលថែទាំរបស់អ្នក ដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក




**គម្រោងមួយ។ ប័ណ្ណមួយ។ Senior Whole Health។**

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបានអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ATTENTION: If you speak a language other than English, language assistance services, free of charge, are available to you. Call 1-888-794-7268 (TTY 711). ATENCIÓN: si hablas español, tienes a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711). ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711).*

Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយរដ្ឋម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យាពេលឆ្នាំ។ ផែនការនេះអាចប្រើបានសម្រាប់អ្នកដែលមានអាយុ 65 ឆ្នាំឡើងទៅដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋនិង Medicare។ H2224_2019_71805

**SWH**
**SENIOR WHOLE HEALTH®**
**Simple. Secure. Independent.**

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
**(TTY 711)**
**www.seniorwholehealth.com/SNP**
ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។



## ដំណឹងជ្រើសរើសជាងធ្វើក្រចក

ហាងយើងខ្ញុំកំពុងតែត្រូវការជាងធ្វើក្រចកជាច្រើននាក់ប្រចាំហាង Pro Nails & Spa
(នៅជិត ឡូវែល និងឡូរិន)
ទីតាំងមានអតិថិជនច្រើនដែលមានប្រាក់ចំណូល និងលុយព្រៅច្រើន
សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមទូរស័ព្ទលេខ
**978-262-2202 or 781-475-6335**

"We are currently hiring at Pro Nails and Spa at Billerica (Near Lowell and Lawrence).
It is a busy location with high income and tips. Please call: 978-262-2202 or 781-475-6335
for more information."



## ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
# URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
**Residential Leasing Center**



ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ
**Daniel Tan**
**Real Estate Agent**
**Cell: 978-902-6354**

**508 Westford Street • Lowell, MA 01851**
**(978) 454-0444**



## ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**



## ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី
# KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
**Car • Home • Business**

**508 Westford Street**
**Lowell, MA 01851**
**978-970-2212**
**kk@kkinsurancema.com**



# អ្នកស្រីក្រុមប្រឹក្សាក្រុងឡុងប៊ិច លីណាហ្គូន ហ្សាលេស ជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាថ្នាក់រដ្ឋ

ដោយ សុបិន ពិន

ឡុងប៊ិច - រដ្ឋកាលីហ្វញ៉ា៖ លោកស្រីក្រុមប្រឹក្សាក្រុង លីណា ហ្គូនហ្សាលេស បានឈ្នះការ




ប្រកួតប្រជែងតំណែងជាសមាជិកព្រឹទ្ធសភាក្នុងការបោះឆ្នោតពិសេសមួយកាលពីថ្ងៃទី៤ ខែមិថុនានេះ។ កៅអីសមាជិកព្រឹទ្ធសភានេះ គឺនៅទំនេរចាប់តាំងពីថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩ មកម្ល៉េះ នៅពេលដែលលោកព្រឹទ្ធសមាជិក រីកាដូ ឡារា ត្រូវបានជាប់ឆ្នោតជាប្រធានការិយាល័យស្នងការធានារ៉ាប់រងរដ្ឋកាលីហ្វញ៉ានៅក្នុងការបោះឆ្នោតពាក់កណ្តាលនៅខែវិច្ឆិកា ឆ្នាំ២០១៨ ។

អ្នកមានសិទ្ធិបោះឆ្នោតខ្មែរអាមេរិកកាំងជាច្រើននៅក្នុងក្រុងឡុងប៊ិចបានងាកទៅចូលរួមបោះឆ្នោតនេះ។ នៅក្នុងកំឡុងពេលនៃការថ្លែងសន្ទរកថាពីការជោគជ័យរបស់លោកស្រីនៅសណ្ឋាគារម៉ាយ៉ា ដុបបូលទ្រីក្នុងទីក្រុងឡុងប៊ិច លោកស្រីព្រឹទ្ធសមាជី ហ្គូនហ្សាលេស បានមានប្រសាសន៍ថា "ខ្ញុំចង់ប្រាប់អ្នកថា សហគមន៍ខ្មែរនៅទីក្រុងឡុងប៊ិចគឺមានសភាពខ្លាំងក្លាណាស់។ ក្នុងការបោះឆ្នោតពិសេសនេះ មានអ្នកបោះឆ្នោតតែ១២% ប៉ុណ្ណោះដែលបានបោះឆ្នោតក្នុងនោះអ្នកបោះឆ្នោតខ្មែរដែលបានចេញទៅបោះឆ្នោតនេះ មានចំនួនដល់ទៅ២៥%"។ ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍ខ្មែរជាច្រើនបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងយុទ្ធនាការថ្នាក់មូលដ្ឋានរបស់លោកស្រី រួមមានការធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយ និងការផ្ញើសារទៅកាន់អ្នកបោះឆ្នោតជាភាសាខ្មែរ។ លោកស្រី សុង ឆាលីស បានមានប្រសាសន៍ថា "តាមរយៈបទពិសោធរបស់ខ្ញុំ ខ្ញុំជឿជាក់ថាលោកស្រីគឺត្រង់ នឹងស្មោះត្រង់ ហើយវាជាពេលលាដ៏មានមោទនៈភាពបំផុតសម្រាប់យើងទាំងអស់គ្នា នៅពេលលោកស្រីបានទទួលស្គាល់សហគមន៍របស់យើងនៅចំពោះមុខអ្នកគាំទ្ររបស់លោកស្រី"។

លោកស្រី ហ្គូនហ្សាលេស បានបម្រើការជាក្រុមប្រឹក្សាក្រុងឡុងប៊ិចអស់រយៈពេល១០ឆ្នាំមកហើយ។ លោកស្រីទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រនយោបាយមកពីសាកលវិទ្យាល័យឡុងប៊ិចកាលីហ្វ័រញ៉ា និងអនុបណ្ឌិតជាន់ខ្ពស់ពីសាកលវិទ្យាល័យឡូយ៉ាឡូ ម៉ារីម៉ុន (Loyola Marymount University)។ អាណត្តិរបស់លោកស្រីនឹងត្រូវបញ្ចប់នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០ ដែលមានន័យថា នឹងអាចមានការបោះឆ្នោតជាទូទៅមួយផ្សេងទៀតនៅរដូវស្លឹកឈើជ្រុះឆ្នាំក្រោយ ហើយប្រសិនបើមានបេក្ខភាពណាមួយកាន់កាប់កៅអីនេះ រឺប្រសិនបើលោកស្រីបន្តកាន់ដំណាងនេះនៅអាណត្តិបន្ទាប់ដោយគ្មានបេក្ខជនផ្សេងទៀត។




From left to right: Suely Saro, Candidate for the 6th District Council seat; Charles Song, Chanbopha Son, Student Volunteers, Mark Hopson, Chan Hopson, State Senator -elect Lena Gonzalez, Roth Prom, Keatha Kong, Chilynna Lo, Chi Ha, and Mr. Vuong.

# Long Beach Councilwoman Lena Gonzalez won State Senate

By Soben Pin

Long Beach, CA — City Councilwoman Lena Gonzalez Won her bid for state Senate on June 4 in a special election. The Senate seat was vacant since January 7, 2019 when Senator Ricardo Lara was elected as insurance commissioner in the midterm election in November 2018.

Strong Cambodian American voters block in Long Beach turned out to vote. “Let me tell you about the Cambodian community, we usually have 8% voters turned during a special election, this time we got up to 12%, and the Cambodian in our universe came out at 25%” said Senator elect Gonzalez during her victory speech at the Hotel Maya Double Tree in Long Beach. Many Cambodian community leaders and members played integral part on her grassroots campaign including door-knocking and phone banks in Khmer language. “From my experience, I believe she was genuine and real and it was a proud moment for us when she acknowledged our community in front of her crowds” said Charles Song.

Gonzalez serves as Long Beach Councilwoman in the last ten years. She holds a Bachelor’s degree in Political Science from California State University Long Beach and an Executive MBA from Loyola Marymount University. Senator elect Lena Gonzalez will represent District 33, which includes Long Beach, Lakewood, Signal Hill and Southeast Los Angeles. Her unexpired term will end on December 7, 2020, which means there maybe another race in the general election in the next fall. If no one runs for the seat, she will continue to serve the next term by default.

បង្កើតផ្ទះដែលលោក-អ្នកស្រឡាញ់

ដាក់ពាក្យយ៉ាងងាយស្រួលតាមអនឡាញ ដោយឥតគិតថ្លៃ!

EnterpriseBanking.com/Mortgage
978-656-5653 | 877-671-2265



សន្សំបាន $500
ទៅលើថ្លៃបិទសំណុំរឿងទិញផ្ទះរបស់លោកអ្នក!*
មជ្ឈមណ្ឌលនិក្ខេប
នៅធនាគារអេនធើប្រៃស៍

Member FDIC
Enterprise Bank
CREATE SUCCESS